ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ទស្សនទាន

## សម្រាប់រៀបចំមុខងារ និងអង្គការលេខ

### ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រាប់ផ្តល់ជាតុចូលដើម្បីកែសម្រួល
អនុក្រឹត្យលេខ៥៤ អនក្រ.បក ប្រកាសលេខ ០៦៦ ស.អ.យ
និងរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី

**រៀបចំដោយ ម៉ៅ វណ្ណា**
**ទីប្រឹក្សាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**ធ្វើនៅឆ្នាំ២០២០**

# មាតិកា


**១.  សេចក្តីផ្តើម ........ ១**

**១.១. សាវតា និងបរិបទ ........ ១**

**១.២. ក្រសួង ស.អ.យ ........ ១**

១.២.១. វិស័យសង្គមកិច្ច ........ ១

១.២.២. វិស័យអតីតយុទ្ធជន ........ ២

១.២.៣. វិស័យយុវនីតិសម្បទា ........ ២

**១.៣. សេវាសាធារណៈរបស់ក្រសួង ស.អ.យ ........ ៣**

**១.៤. មន្ទីរ ស.អ.យ រាជធានី ខេត្ត ........ ៤**

**២.  កំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលមូលដ្ឋាន ........ ៧**

**២.១.ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ........ ៨**

២.១.១.អនុក្រឹត្យលេខ ៣៤ អនក្រ.បក ........ ៩

២.១.២.ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ ........ ១០

២.១.៣.គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ ........ ១២

**៣.  សកម្មភាពមានកំណត់នៅក្នុងគោលនយោបាយ ........ ១៨**

**៣.១. ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ........ ១៨**

៣.១.១.ប្រព័ន្ធជំនួយសង្គម ........ ១៨

៣.១.២.ប្រព័ន្ធសន្តិសុខសង្គម ........ ១៩

**៣.២. គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ ........ ១៩**

**៣.៣. គោលនយោបាយជាតិប្រជាជន ២០១៧-២០៣០ ........ ១៩**

**៣.៤. គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ២០០៦ ........ ២០**

៣.៤.១.ការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល ........ ២០

៣.៤.២.ការប្តេជ្ញាចិត្តរបស់មន្ត្រី និងភ្នាក់ងារផ្តល់ការថែទាំជំនួស ........ ២០

**៣.៥. គោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩ ........ ២១**

៣.៥.១.ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ ........ ២១

៣.៥.២.ប្រព័ន្ធអន្តរាគមន៍ ........ ២២

៣.៥.៣.ប្រព័ន្ធឆ្លើយតបនិងផ្តល់សេវា ........ ២២

**៤. សកម្មភាពមានកំណត់នៅក្នុងច្បាប់**........................................................................ ២៣
**៤.១. ច្បាប់យុត្តិធម៌អនីតិជន**............................................................................................ ២៣
**៤.២. ច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន**.............................................................................. ២៤
៤.២.១.វិធាននៃការគ្រប់គ្រងការព្យាបាល និងស្តារនីតិសម្បទា........................................................ ២៤
៤.២.២.ការព្យាបាល និងស្តារនីតិសម្បទា ................................................................................ ២៥
**៤.៣. ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ** ........................................................ ២៥
**៤.៤. ច្បាប់ស្តីសុំកូនអន្តរប្រទេស**........................................................................................ ២៧
៤.៤.១.អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ............................................................................. ២៧
៤.៤.២.រដ្ឋបាលសុំកូនអន្តរប្រទេស ........................................................................................ ២៧

## ១. សេចក្តីផ្តើម

### ១.១. សាវតា និងបរិបទ

ការងារសង្គមកិច្ចបានចាប់ផ្តើមកើតឡើងនៅចុងឆ្នាំ១៨០០ នៅសហរដ្ឋអាមេរិក និងអឺរ៉ុប នៅពេលដែលសង្គមគាំទ្រឱ្យមានការផ្លាស់ប្តូរបានកើតឡើងជាមួយនឹងបដិវត្តឧស្សាហកម្ម។ ជាច្រើនសតវត្សរ៍មកនេះបុគ្គលិកសង្គមកិច្ចនៅក្នុងប្រទេសទាំងនេះបានចាប់ដំណើរការមួយដ៏វែងឆ្ងាយសំដៅបង្កើតបទដ្ឋានសម្រាប់ការអប់រំ និងរៀបចំធ្វើឱ្យការងារសង្គមកិច្ចមានវិជ្ជាជីវៈ គឺសំដៅអភិវឌ្ឍចំណេះដឹងឯកទេសដែលប្រើប្រាស់ព័ត៌មានទ្រឹស្តី និងការអនុវត្តផ្ទាល់ដើម្បីដោះស្រាយបញ្ហាមនុស្ស និងបញ្ហាសង្គម។[1] ដោយឡែកការងារសង្គមកិច្ចនៅក្នុងកម្ពុជា ចាប់ផ្តើមមានស្ថាប័នដឹកនាំដំបូងមានឈ្មោះ "ក្រសួងព័ត៌មាន និងសង្គមកិច្ច នៅឆ្នាំ១៩៤៧ និងបានផ្លាស់ប្តូរឈ្មោះស្ថាប័ន និងឈ្មោះថ្នាក់ដឹកនាំជាបន្តបន្ទាប់ទៅតាមសម័យកាលនៃរបបដឹកនាំនីមួយៗ[2] ដែលបច្ចុប្បន្ននេះមានឈ្មោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[3] មានឯកឧត្តម **វង សូត** ជារដ្ឋមន្ត្រីនៅក្នុងរាជរដ្ឋាភិបាលអាណត្តិទី៦ នៃរដ្ឋសភាដែលមានសម្តេចអគ្គមហាសេនាបតី **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

### ១.២. ក្រសួង ស.អ.យ

ក្រសួង ស.អ.យ បង្កើតឡើងដោយច្បាប់ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥។ អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស.អ.យ។ មាត្រា ៣. ក្រសួង ស.អ.យ មានភារកិច្ចដូចតទៅៈ

#### ១.២.១. វិស័យសង្គមកិច្ច

- រៀបចំគោលនយោបាយ និងដឹកនាំគ្រប់គ្រងរាល់សង្គមកិច្ចរបស់រដ្ឋដើម្បីជួយដល់ប្រភេទជនងាយរងគ្រោះ និងក្រីក្រជាអាទិ៍ៈ ជនចាស់ជរាគ្មានទីពឹង ជនពិការ ជនរស់នៅតាមចិញ្ចើមថ្នល់ កុមារកំព្រា កុមារតាមចិញ្ចើមថ្នល់ ស្រីពេស្យា (ស្ត្រីបំរើសេវាកំសាន្ត) ជនដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងមានមេរោគឆ្លងកាចសាហាវ ជនក្រីក្រជួបការលំបាកជាងគេក្នុងសង្គម
- រៀបចំអនុវត្តគោលនយោបាយស្តីពីគ្រួសារ ជនចាស់ជរា
- រៀបចំលិខិតបទដ្ឋាន និងគ្រប់គ្រងការងារសុំកូនទៅចិញ្ចឹមនៅក្នុងនិងក្រៅប្រទេស
- រៀបចំសេវាសង្គមកិច្ចដើម្បីថែរក្សា ការពារ និងអប់រំកុមារកំព្រា កុមាររងគ្រោះដោយអំពើជួញដូរ ដោយជំងឺអេដស៍ កុមារពិការ និងចិញ្ចឹមបីបាច់ថែរក្សាទារកដែលត្រូវគេបោះបង់ចោល
- រៀបចំគោលការណ៍គាំពារជនពិការ អនុវត្តការងារស្តារលទ្ធភាពពលកម្ម បង្កលក្ខណៈខាងជីវភាពរស់នៅដល់ជនពិការគ្រប់ប្រភេទ
- សហការជាមួយស្ថាប័នពាក់ព័ន្ធចាត់វិធានការផ្លូវច្បាប់ក្នុងការទប់ស្កាត់អំពើពេស្យាចារ ការជួញដូរមនុស្ស ការរំលោភផ្លូវភេទលើកុមារ ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍
- សហការជាមួយស្ថាប័នពាក់ព័ន្ធជួយដល់ជនរងគ្រោះដោយភយន្តរាយផ្សេងៗមានគ្រោះថ្នាក់ធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗទៀត

---

[1] http://ifsw.org/what-we-do/governance/constitution-and-by-laws/

[2] ឯកសារស្រាវជ្រាវដោយលោក ពុយ គា រាជរដ្ឋាភិបាលកម្ពុជាពីឆ្នាំ១៩៤៥ ដល់ឆ្នាំ២០១០ ចេញផ្សាយថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០។

[3] ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ស.អ.យ

- សហការជាមួយស្ថាប័ន និងអង្គការពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិកុមារគ្រប់គ្រងរបបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការតាមការកំណត់របស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- គ្រប់គ្រងរបបធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញភារកិច្ច
- គ្រប់គ្រងរបបធានារ៉ាប់រងសង្គមដល់កូនកំព្រាពីសពមន្ត្រីរាជការ
- ដឹកនាំគ្រប់គ្រង និងសហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិដែលធ្វើសកម្មភាពលើវិស័យសង្គមកិច្ចជាអាទិ៍ ការផ្តល់ព័ត៌មាន ការប្រាប់បង្ហាញ ការណែនាំ និងការផ្តល់សេវាសង្គមកិច្ចនានា
- បំផុលការចូលរួមសកម្មភាពសាមគ្គីធម៌សង្គម លើកទឹកចិត្ត និងធ្វើជាដៃគូជាមួយអង្គការមនុស្សធម៌ សហគមន៍មូលដ្ឋាន ក្នុងការបង្កើតមូលនិធិទ្រទ្រង់ដល់សេវាសង្គមកិច្ចនានាដើម្បីជួយដល់ជនងាយរងគ្រោះគ្រប់ប្រភេទ។

## ១.២.២. វិស័យអតីតយុទ្ធជន

- រៀបចំដាក់ឱ្យដំណើរការ សម្របសម្រួលគោលនយោបាយជាតិស្តីពីអតីតយុទ្ធជន
- រៀបចំបញ្ចូលអតីតយុទ្ធជន និងគ្រួសារទៅក្នុងសហគមន៍ដោយលើកកម្ពស់ស្ថានភាពរស់នៅឱ្យបានល្អប្រសើរនិងគ្មានការរើសអើងតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ការដោះស្រាយការងារធ្វើនិងបង្កើតមុខរបរ
- លើកគោលការណ៍អប់រំណែនាំអតីតយុទ្ធជនឱ្យយល់ពីតម្លៃកាតព្វកិច្ច តួនាទីក្នុងគ្រួសារ សហគមន៍ និង សង្គមដើម្បីទទួលបានការអភិវឌ្ឍ
- គ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទតាមការកំណត់របស់ច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- គ្រប់គ្រង និងដោះស្រាយគោលនយោបាយជូនជនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន ពិការ និងគ្រួសារនៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងសេនាជន កងជីវពលដែលបានបូជាជីវិតដើម្បីប្រទេសជាតិ។

## ១.២.៣. វិស័យយុវនីតិសម្បទា

- គ្រប់គ្រងក្មេងពីអាយុ៧ឆ្នាំដល់ក្រោម១៨ឆ្នាំដែលបានប្រព្រឹត្តបទល្មើស ពាលអនាថា អបាយមុខក្នុងទូទាំងប្រទេស និងមានតួនាទីកែប្រែអប់រំដើម្បីឱ្យក្លាយទៅជាពលរដ្ឋល្អ
- បង្កើតមណ្ឌលទទួលអប់រំកុមារ តាមការចាំបាច់ដើម្បីទទួលយកកុមារដែលបានប្រព្រឹត្តអំពើខុសឆ្គងមកគ្រប់គ្រង អប់រំ និងបណ្តុះបណ្តាល
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ បង្កើតកម្មវិធីអប់រំបណ្តុះបណ្តាលអនីតិជន
- សហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិតតាមពន្ធនាគារ
- កសាងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធទៅនឹងការគ្រប់គ្រងវិស័យយុវនីតិសម្បទា
- បង្កើត និងគ្រប់គ្រងមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងសមាហរណកម្មជនរងគ្រោះទាំងនោះទៅក្នុងសហគមន៍

## ១.៣. សេវាសាធារណៈរបស់ក្រសួង ស.អ.យ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានរៀបចំតាក់តែងសៀវភៅសេវាសាធារណៈគឺទទួលបានជាតុចូលពីគ្រប់ផ្នែក និងអ្នកពាក់ព័ន្ធក្នុងការផ្តល់សេវា និងបានធ្វើបច្ចុប្បន្នភាព នៅថ្ងៃទី២៣ ខែមិនា ឆ្នាំ២០២០។ ឯកសារនេះឆ្លុះបញ្ចាំងអំពីប្រភេទសេវា បែបបទ នីតិវិធីនៃការផ្តល់ ឬទទួលបានសេវា និងឯកសារគាំទ្រចាំបាច់នានាដើម្បីទទួលបានសេវាពីនីតិបុគ្គល ជាអង្គភាព ឬមន្ត្រីរបស់ក្រសួង ស.អ.យ។ កម្រងសេវាសាធារណៈរួមមាន៖

- ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយជាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍
- ការផ្តល់សេវាថែទាំ គាំទ្រដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍និងរងផលប៉ះពាល់ដោយ សារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗ នៅតាមសហគមន៍
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ(ប្រព័ន្ធជំនួយសង្គម)
- ការដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា
- ទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី
- សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ
- មាតុភូមិនិវត្ត ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន
- សេវាថែទាំជំនួសចំពោះកុមារ
- ការផ្តល់អាជ្ញាប័ណ្ណដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស
- ការទុកដាក់កុមារជាមួយគ្រួសារអេចិន្ត្រៃយ៍នៅប្រទេសទទួល
- ការផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន
- ការផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់
- របបគោលនយោបាយឧបត្ថម្ភចំពោះជនពិការក្រីក្រនៅតាមសហគមន៍(ប្រព័ន្ធជំនួយសង្គម)
- សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ
- សេវាចុះបញ្ជិកាលើការអនុវត្តច្បាប់ពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- អន្តរាគមន៍សេវាយុត្តិធម៌សម្រាប់ជនពិការ
- ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា
- សេវាស្តារលទ្ធភាពពលកម្ម និងរបបគោលនយោបាយផ្នែកពិនិត្យ ព្យាបាល និងថែទាំសុខភាពចំពោះជនពិការក្រីក្រតាមសហគមន៍(មូលនិធិជនពិការ)
- ការផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក(ប្រព័ន្ធសន្តិសុខសង្គម)
- ការបើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន(ប្រព័ន្ធសន្តិសុខសង្គម)
- ការផ្តល់សេវាជួយដល់អតីតយុទ្ធជននៅតាមសហគមន៍
- ការអប់រំ និងបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា

រូបភាពទី១៖ អង្គការលេខរបស់ក្រសួង ស.អ.យ




## ១.៤. មន្ទីរ ស.អ.យ រាជធានី ខេត្ត

ក្រសួង ស.អ.យ បានប្រកាសលេខ ០៦៦ ស.អ.យ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត ជំនួសឱ្យប្រកាសលេខ ៣៥៩ ស.អ.យ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្យទៅរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត។ ប្រការ ២ នៃប្រកាសលេខ ០៦៦ ស.អ.យ មន្ទីរ ស.អ.យ មានភារកិច្ច៖

**ក.ការងាររដ្ឋបាល**

**ខ.វិស័យសង្គមកិច្ច**

- ដឹកនាំអនុវត្តគោលនយោបាយ និងគ្រប់គ្រងរាល់សង្គមកិច្ចរបស់រដ្ឋដើម្បីជួយដល់ប្រភេទជនងាយរងគ្រោះ និងក្រីក្រជាអាទិ៍: ជនចាស់ជរាគ្មានទីពឹង ជនពិការ ជនរស់នៅតាមចិញ្ចើមថ្នល់ កុមារកំព្រា កុមារតាមចិញ្ចើមថ្នល់ ស្រីពេស្យា (ស្ត្រីបំរើសេវាកំសាន្ត) ជនដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងមានមេរោគឆ្លងកាចសាហាវ ជនក្រីក្រជួបការលំបាកជាងគេក្នុងសង្គម

- អនុវត្តគោលនយោបាយស្តីពីគ្រួសារ ជនចាស់ជរា
- រៀបចំសេវាសង្គមកិច្ចដើម្បីថែរក្សា ការពារ និងអប់រំកុមារកំព្រា កុមាររងគ្រោះដោយអំពើជួញដូរ ដោយជំងឺអេដស៍ កុមារពិការ និងចិញ្ចឹមបីបាច់ថែរក្សាទារកដែលត្រូវគេបោះបង់ចោល
- សហការជាមួយស្ថាប័នពាក់ព័ន្ធចាត់វិធានការផ្លូវច្បាប់ក្នុងការទប់ស្កាត់អំពើពេស្យាចារ ការជួញដូរមនុស្ស ការរំលោភផ្លូវភេទលើកុមារ ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍
- សហការជាមួយស្ថាប័នពាក់ព័ន្ធជួយដល់ជនរងគ្រោះដោយភយន្តរាយផ្សេងៗមានគ្រោះថ្នាក់ធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗទៀត
- អនុវត្តគោលនយោបាយស្តារលទ្ធភាពពលកម្មកាយសម្បទាដោយបង្កលក្ខណៈខាងជីវភាពរស់នៅដល់ជនពិការគ្រប់ប្រភេទ
- ជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- រៀបចំការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការដោះស្រាយមុខរបរនិងការងារជូនជនពិការ
- សម្របសម្រួលការងារជាមួយមូលនិធិជនពិការក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម
- បំផុសសកម្មភាពវប្បធម៌ សិល្បៈ កីឡាជនពិការ
- គ្រប់គ្រងសាខារដ្ឋបាលលិទ្ធិជនពិការដោយអនុវត្តតាមប្រកាសលេខ ០៥៦ ស.អ.យ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ ស្តីពីការបង្កើតរដ្ឋបាលសិទ្ធិជនពិការ
- សម្របសម្រួលការងារជាមួយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលរាជធានីខេត្តដើម្បីជំរុញនិងធានាការបើកផ្តល់នូវតាវកាលិកទាំងឡាយសម្រាប់សមាជិកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- សហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសជាដៃគូដែលធ្វើសកម្មភាពលើវិស័យសង្គមកិច្ចនៅក្នុងរាជធានី ខេត្ត ជាអាទិ៍ ការផ្តល់ព័ត៌មាន ការណែនាំ និងការផ្តល់សេវាសង្គមកិច្ចនានា
- បំផុសឱ្យមានការចូលរួមសកម្មភាពសាមគ្គីធម៌សង្គម លើកទឹកចិត្ត និងធ្វើជាដៃគូជាមួយអង្គការមនុស្សធម៌សហគមន៍មូលដ្ឋាន ក្នុងការបង្កើតមូលនិធិទ្រទ្រង់ដល់សេវាសង្គមកិច្ចនានាដើម្បីជួយដល់ជនរងគ្រោះគ្រប់ប្រភេទ។

**គ.វិស័យអតីតយុទ្ធជន**

- អនុវត្តគោលនយោបាយជាតិស្តីពីអតីតយុទ្ធជន
- សម្របសម្រួលការងារជាមួយបេឡាជាតិអតីតយុទ្ធជន
- សម្របសម្រួលការងារជាមួយមូលនិធិជនពិការ
- អប់រំ ណែនាំអតីតយុទ្ធជនឱ្យយល់ពីតម្លៃ កាតព្វកិច្ច តួនាទីក្នុងគ្រួសារ សហគមន៍ និងសង្គមដើម្បីទទួលបានការអភិវឌ្ឍ
- សម្របសម្រួលជាមួយអាជ្ញាធរដែនដីដើម្បីទាក់ទាញការជួយឧបត្ថម្ភគាំទ្រចំពោះអតីតយុទ្ធជន

**ឃ.វិស័យយុវនីតិសម្បទា**

- គ្រប់គ្រងក្មេងពីអាយុ៧ឆ្នាំដល់ក្រោម១៨ឆ្នាំដែលបានប្រព្រឹត្តបទល្មើស ពាលអនាថា អបាយមុខក្នុងទូទាំងប្រទេស និងមានតួនាទីកែប្រែអប់រំដើម្បីឲ្យក្លាយទៅជាពលរដ្ឋល្អ

- គ្រប់គ្រងមណ្ឌលយុវនីតិសម្បទាដើម្បីទទួលយកកុមារដែលបានប្រព្រឹត្តអំពើខុសឆ្គងមកគ្រប់គ្រង អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការជាមួយអង្គភាពពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ បង្កើតកម្មវិធីអប់រំបណ្តុះ បណ្តាលអនីតិជន
- សហការជាមួយឪពុកម្តាយ ឬអាណាព្យាបាល និងអាជ្ញាធរមូលដ្ឋានក្នុងការបញ្ជូនកុមារ អនីតិជន ដែលជាជនរងគ្រោះដោយការប្រើប្រាស់គ្រឿងញៀនទៅក្នុងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនតាមការស្ម័គ្រចិត្ត ឬតាមការបញ្ជូនរបស់អាជ្ញាធរដើម្បីធ្វើការព្យាបាល និងស្តារនីតិសម្បទា និងធ្វើសមាហរណកម្មជនរងគ្រោះទាំងនោះទៅក្នុងសហគមន៍វិញ

ប្រកាសលេខ ០៦៦ ស.អ.យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរ ស.អ.យ បានធ្វើវិកាករណ៍ប្រកាសលេខ ៣៩៥ ស.អ.យ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៥។ ប្រការ ៦ នៃប្រកាសលេខ ០៦៦ បានកំណត់តួនាទីនិងភារកិច្ចរបស់**ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**មានដូចខាងក្រោម៖

- ជាសេនាធិការឱ្យមន្ទីរ ស.អ.យ រាជធានី ខេត្ត ក្នុងការអនុវត្តផ្ទាល់ និងដាក់ស្តែងនៃការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងដែនសមត្ថកិច្ច ក្រុង ស្រុក ខណ្ឌ នោះ
- សហការ និងសម្របសម្រួលការងារជាមួយរដ្ឋបាល ក្រុង ស្រុក ខណ្ឌ
- ប្រមូលព័ត៌មានស្តីពីស្ថានភាពប្រជាជនដែលងាយរងគ្រោះ និងទទួលរងគ្រោះក្នុងក្រុង ស្រុក ខណ្ឌ មានជាអាទិ៍ ជនអនាថា កុមារដែលប្រព្រឹត្តអំពើល្មើសច្បាប់ ជនចាស់ជរាគ្មានទីពឹង កុមារកំព្រា កុមារត្រូវគេបោះបង់ចោល ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រជាជនរងគ្រោះដោយធម្មជាតិ អគ្គីភ័យ ខ្យល់ព្យុះ ទឹកជំនន់ ។ល។
- ធ្វើការតាមដានស្ថានភាព ជីវភាពរស់នៅរបស់និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងគ្រួសារដើម្បីជួយសម្រួលបញ្ហាបានទាន់ពេលវេលា
- អនុវត្តកម្មវិធីសមហរណកម្មជនរងគ្រោះ និងជនអនាថារបស់មន្ទីរ
- តាមដានស្រាវជ្រាវជីវភាពរស់នៅនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងគ្រួសារដើម្បីជួយសម្របសម្រួលបញ្ហាឱ្យបានទាន់ពេលវេលា
- ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ក្រោមការត្រួតពិត្យរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត
- លើកទិសដៅផែនការដាក់ស្តែងលើការងារជំនាញ
- សហការជាមួយអង្គការនានាដែលប្រតិបត្តិការក្នុងក្រុង ស្រុក ខណ្ឌ របស់ខ្លួន
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងចងក្រងទិន្នន័យ ព័ត៌មាន ស្ថិតិ ដែលជាតម្រូវការរបស់មន្ទីរ
- សម្របសម្រួលការងារជាមួយមន្ទីរនៅថ្នាក់មូលដ្ឋានរបស់ខ្លួន
- រៀបចំផែនការសម្រាប់ការងាររដ្ឋបាល និងធ្វើរបាយការណ៍សកម្មភាពការងារ
- ទទួលខុសត្រូវ គ្រប់គ្រង ទុកដាក់ ការពារ និងថែរក្សាការសម្ងាត់ រាល់ឯកសារ លិខិតយុត្តិការ និងសក្ខីប័ត្រពាក់ព័ន្ធនានា
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនមន្ទីរ
- ការងារផ្សេងៗទៀត ដែលប្រគល់ឱ្យដោយប្រធានមន្ទីរ ស.អ.យ

ការិយាល័យ ស.អ.យ ក្រុង ស្រុក ខណ្ឌ និងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន មូលនិធិជនពិការ ក្រុង ស្រុក ខណ្ឌ ត្រូវសហការ និងសម្របសម្រួលការងារឱ្យបានល្អប្រសើរ។

រូបភាពទី២៖ អង្គការលេខរបស់មន្ទីរ ស.អ.យ




## ២. កំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលមូលដ្ឋាន

កំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅរដ្ឋបាលមូលដ្ឋានគឺជាលទ្ធផលនៃប្រវត្តិជោគជ័យពីការអនុវត្តគម្រោងល្បីមួយដែលត្រូវបានគេស្គាល់ថា "សីលា"។ ចាប់ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០០ គម្រោងនេះ ត្រូវបានយកទៅអនុវត្តនៅតាមបណ្តាឃុំ-សង្កាត់ខ្លះនៅក្នុងខេត្តគោលដៅមួយចំនួនសំដៅដោះស្រាយតម្រូវការនៅតាមទីជនបទដោយប្រសិទ្ធភាព ដោយការផ្ទេរទៅឱ្យរដ្ឋបាលមូលដ្ឋាន នូវធនធានហិរញ្ញវត្ថុ និងអំណាចធ្វើសេចក្តីសម្រេចចិត្ត។[4] យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ច្បាប់ស្តីពីការគ្រប់

- [4] បុគ្គលិកសារព័ត៌មានភ្នំពេញប៉ុស្តិ៍. "សីលា ផ្តល់ឱកាសឱ្យប្រជាជនដឹកនាំខ្លួនឯង." ភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០០។ ចូលអាននៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៥។ http://www.phnompenhpost.com/national/seila-seeks-give-people-selfgovernment . សម្រាប់សិក្សាបន្ថែម Henny Andersen. យន្តការវិមជ្ឈការឈ្មោះទៅការអភិវឌ្ឍជនបទ និងកាត់បន្ថយភាពក្រីក្រ. ធនាគារអន្តរជាតិសម្រាប់ការកសាងឡើងវិញ និង អភិវឌ្ឍន៍: ឆ្នាំ២០០៤។ http://documents.worldbank.org/curated/en/990781468231553040/Cambodias-Seila-program-a-decentralized-approach-to-rural-development-and-poverty-reduction

គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក និងខណ្ឌ។ ទន្ទឹមនឹងក៏បានធ្វើការដកស្រង់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផែនការអនុវត្តន៍៣ឆ្នាំដំណាក់កាលទី១(ផអ៣ទី១)ដែលមានរយៈពេល៣ឆ្នាំ+០១ឆ្នាំ(២០១១-២០១៤)ផែនការអនុវត្តន៍រយៈពេល៣ឆ្នាំដំណាក់កាលទី២ (ផអ៣ទី២) ដែលមានរយៈពេល (២០១៥-២០១៧) និងផែនការអនុវត្តន៍រយៈពេល៣ឆ្នាំ(២០១៨-២០២០)។

រូបភាពទី៣៖ ខ្សែពេលវេលានៃដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា




*ប្រភព៖ បទបង្ហាញរបស់ឯកឧត្តម សក់ សេដ្ឋា*

## ២.១.ការផ្ទេរមុខងារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេមុខងារ និងធនធានឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អនុក្រឹត្យនេះមានគោលបំណងជានាទូវការផ្ទេរមុខងារ និងធនធានពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយមានលក្ខណៈជាប្រព័ន្ធ តាមដំណាក់កាល មានសនិទានភាព ការសម្របសម្រួល ការពិគ្រោះយោបល់ តម្លាភាព និងប្រកបដោយសមធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍ។ អនុក្រឹត្យលេខ៦៨ អនក្រ.បក បានតម្រូវឱ្យក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានានិងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវរៀបចំបញ្ជីវិភាគមុខងារក្នុងនោះផ្នែកសង្គមកិច្ចជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពនានាក្នុងដំណើរការផ្ទេមុខងារ និងធនធានឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាលទ្ធផលក្រសួង ស.អ.យ បានធ្វើរបាយការណ៍រៀបចំបញ្ជីវិភាគមុខងារ និងពិនិត្យមើលមុខងារឡើងវិញដើម្បីដាក់ជូន គ.ជ.អ.ប ពិនិត្យ និងសម្រេច។

នៅឆ្នាំ២០១៤ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានរៀបចំផែនការ[5] ដើម្បីអនុវត្តផ្ទេរសេវាថែទាំជំនួសចំពោះកុមារក្នុងនោះមាន៖(១)ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ (២).ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល (៣).ការគ្រប់គ្រងសេវាថែទាំនៅក្នុងសហគមន៍។ បន្ទាប់ពីសាកល្បងផ្ទេរមុខងារទាំងបីខាងលើនេះអស់រយៈពេល៣ឆ្នាំ ក្រសួង ស.អ.យ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ និងដោយមានការគាំទ្រពី គ.ជ.អ.ប បានស្នើដល់រាជរដ្ឋាភិបាលចេញជាអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានីខេត្ត ការប្រគល់មុខងារត្រួតពិនិត្យ

[5] ក្រសួងនឹងសហការជាមួយ គ.ជ.អ.ប អង្គការដៃគូ និងអ្នកពាក់ព័ន្ធដើម្បីរៀបចំផែនការអនុវត្តសាកល្បងផ្ទេរមុខងារនៅឆ្នាំ២០១៤។

មណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក ការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំ កុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។

**២.១.១.អនុក្រឹត្យលេខ ៣៤ អនក្រ.បក**

មាត្រា ៥ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ បានប្រគល់មុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ" ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត រួមមាន៖

- ការពិនិត្យ និងសម្រេចលើសំណុំឯកសារដែលសុំបញ្ចូល ឬបញ្ចេញកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងមណ្ឌលថែទាំកុមាររបស់រដ្ឋ
- ការគ្រប់គ្រង ផ្តល់អាហារ សម្លៀកបំពាក់ ថែទាំសុខភាព អប់រំ វិន័យ សីលធម៌ ការអភិវឌ្ឍក្នុងសង្គមដល់កុមារនៅក្នុងមណ្ឌល និងដោះស្រាយបញ្ហាផ្សេងៗទៀតរបស់កុមារទាំងនោះ
- ការគ្រប់គ្រងករណីកុមារនៅក្នុងមណ្ឌល ការធ្វើសមាហរណកម្ម ការបង្រួបបង្រួមគ្រួសារ ការតាមដាន និងការបិទករណីរបស់កុមារ
- ការរៀបចំផែនការអចិន្ត្រៃយ៍សម្រាប់កុមារនៅក្នុងមណ្ឌលរដ្ឋដើម្បីរកគ្រួសារកុមារ
- ការផ្សព្វផ្សាយការយល់ដឹងអំពីគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការថែទាំជំនួសចំពោះកុមារដល់មន្ត្រី បុគ្គលិកក្រោមឱវាទ និងប្រជាជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការបណ្តុះបណ្តាលបំណិតជីវិត និងជំនាញវិជ្ជាជីវៈនានាសម្រាប់កុមារអាយុច្រើនដែលមិនអាចរកគ្រួសារអចិន្ត្រៃយ៍បានមុនពេលពួកគេឈានដល់ពេញវ័យ
- ការរៀបចំបញ្ជីបច្ចុប្បន្នភាពកុមារនៅក្នុងមណ្ឌលរដ្ឋ និងសំណុំឯកសារដែលត្រូវស្នើសុំកូនធ្វើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

មាត្រា ៦ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ បានប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល"ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក។ រដ្ឋបាលរាជធានីធ្វើប្រតិភូកម្មមុខងារឱ្យរដ្ឋបាលខណ្ឌក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- ធ្វើអធិការកិច្ចលើការអនុវត្តបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។
- ការសម្របសម្រួលដោះស្រាយករណីរំលោភបំពានលើសិទ្ធិកុមារដែលកើតមាននៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល
- គ្រប់គ្រង និងវិភាគទិន្នន័យកុមាររងគ្រោះនិងងាយរងគ្រោះ និងកុមារដែលកំពុងស្ថិតនៅក្នុងការថែទាំជំនួសក្នុងសហគមន៍
- ការរៀបចំបញ្ជីបច្ចុប្បន្នភាព នៃអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតផ្តល់ការថែទាំជំនួសចំពោះកុមារ
- ការជម្រុញលើកទឹកចិត្តឱ្យអង្គការមិនមែនរដ្ឋាភិបាលផ្តល់សេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះ
- ការពិនិត្យនិងសម្រេចលើសំណុំឯកសារដែលសុំ ឬបញ្ចូលកុមាររងគ្រោះនិងងាយរងគ្រោះសម្រាប់មណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល
- ការតាមដានការបញ្ជូនករណីកុមារ និងការផ្តល់សេវាសុខុមាលភាពកុមារនៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។

មាត្រា ៧ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ បានប្រគល់មុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍" ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។ រដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងធ្វើប្រតិភូកម្មមុខងារនេះឱ្យទៅរដ្ឋបាលសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- ការប្រមូលទិន្នន័យកុមាររងគ្រោះ និងងាយរងគ្រោះ និងកុមារដែលកំពុងស្ថិតនៅក្នុងការថែទាំជំនួសក្នុងសហគមន៍
- ការប្រមូលទិន្នន័យអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសនិងអ្នកពាក់ព័ន្ធដើម្បីធ្វើផែនទីសេវាសង្គម
- ការវាយតម្លៃអំពីភាពខ្លាំង ភាពខ្សោយ និងតម្រូវការរបស់កុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ក្នុងគ្រួសារ
- ការរៀបចំផែនការសេវាគ្រួសារនិងស្វែងរកសេវាចាំបាច់នានាដើម្បីរក្សាកុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ក្នុងគ្រួសារឱ្យរស់ជុំគ្រួសារ និងតាមដានដំណើរការវិវឌ្ឍរបស់កុមារទាំងនោះ
- ការសម្រេចបិទករណី ឬទុកដាក់កុមារដែលស្ថិតក្នុងស្ថានភាពប្រឈមគ្រោះថ្នាក់ក្នុងគ្រួសារជាបណ្តោះអាសន្នតាមការថែទាំជំនួស
- ការរៀបចំទុកដាក់ជាបណ្តោះអាសន្ននៅកន្លែងមានសុវត្ថិភាពចំពោះកុមារដែលត្រូវបានគេបោះបង់ចោលតាមរយៈការថែទាំជាមួយសាច់ញាតិកុមារ ជាមួយគ្រួសារធម៌ ជាមួយព្រះសង្ឃ កន្លែងសាសនា ការថែទាំជាក្រុមក្នុងសហគមន៍ ឬមណ្ឌលថែទាំកុមារ។

**២.១.២.ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ**

យោងតាមអនុក្រឹត្យលេខ ១៨២ អនក្រ.បក ១៨៣ អនក្រ.បក និង១៨៤អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ មាត្រា៧១ និងមាត្រា៥៦ ការិយាល័យ និងអង្គភាពជំនាញពាក់ព័ន្ធរបស់ក្រសួង ស្ថាប័ន ដែលមាននៅថ្នាក់ក្រុង ស្រុក និងខណ្ឌត្រូវធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក និងខណ្ឌ។ មាត្រា២៦ និងមាត្រា២២ **ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម** ត្រូវបំពេញតួនាទីជាសេនាការឱ្យរដ្ឋបាលក្រុង ស្រុក និងខណ្ឌលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គម និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចជា៖ **ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ការងារសុខាភិបាល ការងារកិច្ចការនារី ការងារធម្មការនិងសាសនា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ការងារវប្បធម៌និងវិចិត្រសិល្បៈ និងការងារគ្រោះមហន្តរាយ។ ការិយាល័យនេះជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានភារកិច្ចអនុវត្ត និងសហការជាមួយអង្គភាព និងអង្គការមិនរដ្ឋាភិបាលក្នុងស្រុកនិងបរទេសលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដូចខាងក្រោម៖

**១. ការងារកុមារកំព្រានិង កុមារងាយរងគ្រោះ**

ការគ្រប់គ្រងករណីកុមារកំព្រា និងងាយរងគ្រោះ

- គ្រប់គ្រង និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទលើកុមារ
- គ្រប់គ្រង ស្វែងរក និងប៉ាន់ប្រមាណគ្រួសារងាយរងគ្រោះ
- គ្រប់គ្រង តាមដាន និងបិទករណីកុមាររងគ្រោះដែលបានសមាហរណកម្មទៅសហគមន៍
- ផ្សព្វផ្សាយគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទលើកុមារ

**២. ការងារជនរងគ្រោះនិងងាយរងគ្រោះ**

- ការគ្រប់គ្រង និងការកំណត់អត្តសញ្ញាណជនរងគ្រោះនិងងាយរងគ្រោះ

- ប្រមូល និងគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយគ្រោះមហន្តរាយ ជនក្រីក្រនិងគ្រួសារនៅសហគមន៍
- ប្រមូល និងគ្រប់គ្រងទិន្នន័យជនអនាថា
- គ្រប់គ្រង កំណត់អត្តសញ្ញាណ និងតាមដានជនផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍
- គ្រប់គ្រង កំណត់អត្តសញ្ញាណ និងតាមដានស្ត្រីមានផ្ទៃពោះក្រីក្រនិងកុមារក្រោម២ឆ្នាំស្ថិតនៅគ្រួសារក្រីក្រ

**៣. ការងារជនពិការ**

- ការគ្រប់គ្រងជនពិការ និងការផ្តល់ព័ត៌មានសេវាស្តារលទ្ធភាពពលកម្ម
- គ្រប់គ្រង និងចងក្រងទិន្នន័យជនពិការក្រីក្រ ជនពិការភាពទូទៅ ស្ត្រីពិការ កុមារពិការ និងកីឡាករជនពិការ
- គ្រប់គ្រង និងផ្តល់ព័ត៌មានអំពីសេវាកម្មសម្រាប់ជនមានពិការភាព
- គ្រប់គ្រង និងផ្តល់ព័ត៌មានការស្នើសុំផ្តល់សេវាស្តារលទ្ធភាពកម្មដល់ជនពិការ

**៤. ការងារបេឡាជាតិ អតីតយុទ្ធជន និងបេឡាជាតិសន្តិសុខសង្គម**

- ការគ្រប់គ្រង និងកំណត់អត្តសញ្ញាណលើមុខសញ្ញាបេឡាជាតិអតីតយុទ្ធជន និងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- គ្រប់គ្រងទិន្នន័យនិវត្តជន( និវត្តជនចាស់ ថ្មី ផ្លាស់ប្តូរទីលំនៅ ទទួលមរណភាពឬនិវត្តជនត្រូវបានលុបឈ្មោះ)
- គ្រប់គ្រងស្ថិត តាមដាន ត្រួតពិនិត្យស្ថានភាពអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ
- គ្រប់គ្រង និងស្នើសុំផ្ទេរលំនៅដ្ឋានរបស់អតីតយុទ្ធជននិងគ្រួសារ
- គ្រប់គ្រង និងស្នើសុំលុបឈ្មោះអតីតយុទ្ធជនដែលទទួលមរណភាព
- គ្រប់គ្រងទិន្នន័យជនបាត់បង់សម្បទាវិជ្ជាជីវៈ
- គ្រប់គ្រងអ្នកនៅក្នុងបន្ទុករបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ឬអ្នកនៅក្នុងបន្ទុករបស់សពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈមានប្រពន្ធ កូន
- គ្រប់គ្រង និងស្នើសុំលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារដែលផុតសុពលភាពទទួលរបបសន្តិសុខសង្គម
- គ្រប់គ្រង និងស្នើសុំលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារដែលមិនបានបើកប្រាក់របបសន្តិសុខសង្គមរបស់ខ្លួនដោយគ្មានមូលហេតុ
- គ្រប់គ្រង និងស្នើសុំបញ្ចូល ឬលុបអ្នកក្នុងបន្ទុកអតីតយុទ្ធជន និងគ្រួសារដើម្បីបានទទួលរបបឧបត្ថម្ភប្រចាំខែ
- គ្រប់គ្រង និងទទួលសំណើអតីតយុទ្ធជន និងគ្រួសារដែលបានបោះបង់របបសន្តិសុខសង្គម
- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាក្នុងការបញ្ចូល ឬលុបអតីតយុទ្ធជនពីសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា
- គ្រប់គ្រងព័ត៌មានអតីតយុទ្ធជនសម្រាប់ទទួលសេវាសុខភាព ឬសេវានានាពីរដ្ឋ
- សហការជាមួយធនាគារដៃគូក្នុងការគ្រប់គ្រង បើកផ្តល់របបសន្តិសុខសង្គម

**៥. ការងារអតីតយុទ្ធជននិងគ្រួសារ**

- ការគ្រប់គ្រង និងកំណត់អត្តសញ្ញាណអតីតយុទ្ធជន និងគ្រួសារ
- ប្រមូលទិន្នន័យពីស្ថានភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារជនពលីមរណៈ
- ផ្តល់សេវាឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់អតីតយុទ្ធជន និងគ្រួសារជនពលីមរណៈ
- គ្រប់គ្រងទិន្នន័យអតីតយុទ្ធជន និងគ្រួសារដែលទទួលផ្ទះ

**៦. ការងារមណ្ឌលស្តារនីតិសម្បទា**

- ការគ្រប់គ្រង និងសហការជាមួយមណ្ឌលស្តារនីតិសម្បទាខេត្ត

- គ្រប់គ្រងទិន្នន័យអនីតិជនទំនាស់នឹងច្បាប់
- គ្រប់គ្រង តាមដានអនីតិជនដែលបានស្តារនីតិសម្បទាដោយសារញៀនគ្រឿងញៀនក្រោយសមាហរណកម្មទៅសហគមន៍

**៧. ការងារសមាគមមនុស្សវ័យចាស់**

- ការគ្រប់គ្រងទិន្នន័យមនុស្សវ័យចាស់ក្នុងសហគមន៍
- គ្រប់គ្រង និងស្រង់ទិន្នន័យ សមាជិក សមាជិកាសមាគមមនុស្សវ័យចាស់
- ផ្សព្វផ្សាយលក្ខន្តិកៈសមាគមមនុស្សវ័យចាស់
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់ថវិកាវិភាគទានរបស់សមាគមមនុស្សវ័យចាស់

**៨. ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល (អនុក្រឹត្យ ៣៤)**

## ២.១.៣.គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

នៅឆ្នាំ២០០៧គណៈកម្មាធិការសម្រាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប បានចេញសេចក្តីណែនាំលេខ០៨២ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារនៅគ្រប់ឃុំ សង្កាត់(គ.ក.ន.ក)។ ឆ្លងកាត់ការអនុវត្តអស់រយៈពេល ១៣ឆ្នាំកន្លងមកទើបក្រសួងមហាផ្ទៃបានចេញប្រកាស ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ (គ.ក.ន.ក) ដើម្បីជំនួសសេចក្តីណែនាំលេខ០៨២ ស.ណ.ន/គ.ជ.វ.វ។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ "គ.ក.ន.ក" មានសមាសភាពដូចខាងក្រោម ៖

តារាងទី១៖ សមាសភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ១ | មេឃុំ ចៅសង្កាត់ | ប្រធាន |
| ២ | ជំទប់ទី២ ឬចៅសង្កាត់រងទី២ | អនុប្រធាន |
| ៣ | **អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់** | អនុប្រធានអចិន្ត្រៃយ៍ |
| ៤ | ស្មៀនឃុំ សង្កាត់ | សមាជិក |
| ៥ | នាយប៉ុស្តិ៍នគរបាលឃុំ សង្កាត់១រូប | សមាជិក |
| ៦ | នាយក ឬនាយិកាសាលាបឋមសិក្សានៅក្នុងឃុំ សង្កាត់ ០១រូប | សមាជិក |
| ៧ | នាយក ឬនាយិកាសាលាមេត្តេយ្យសិក្សានៅក្នុងឃុំ សង្កាត់ ០១រូប | សមាជិក |
| ៨ | ប្រធានមណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព | សមាជិក |
| ៩ | មេភូមិ ឬអនុប្រធានប្រធានភូមិទាំងអស់នៅក្នុងឃុំ សង្កាត់ | សមាជិក |
| ១០ | តំណាងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជន ឃុំ សង្កាត់០១ រូប | សមាជិក |
| ១១ | តំណាងសមាគមមនុស្សចាស់ ០១ រូប | សមាជិក |
| ១២ | តំណាងជនមានពិការភាព ០១រូប | សមាជិក |
| ១៣ | **ជំនួយការសេវាសង្គមឃុំ សង្កាត់** | ជាលេខាធិការ |

គ.ក.ន.ក មានតួនាទីផ្តល់យោបល់ និងជួយរដ្ឋបាលឃុំ សង្កាត់ក្នុងការសម្របសម្រួល និងការអនុវត្តសកម្មភាពសេវាសង្គមទាំងអស់នៅក្នុងឃុំ សង្កាត់ ដើម្បីធានាថា ស្ត្រី កុមារ យុវជន មនុស្សចាស់ ជនក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងទៀត ទទួលបានព័ត៌មាន ចំណេះដឹង និងសេវានានាប្រកបដោយសមធម៌សង្គម និងបរិយាបន្ន ព្រមទាំងមានជីវភាពរស់នៅប្រកបដោយសុវត្ថិភាព សុខដុមរមនា និងសេចក្តីថ្លៃថ្នូរ។[6] បន្ថែមពីភារកិច្ចខាងលើនេះ គ.ក.ន.ក មានសកម្មភាពសេវាសង្គមសំខាន់ៗរួមមាន[7]៖

**ក)ការងារសុខភាពមាតា ទារក អាហារូបត្ថម្ភ**

- ស្រង់ស្ថិតិស្ត្រីមានផ្ទៃពោះ ទារក និងកុមារស្គមស្គាំង កុមារក្រិសក្រិន ព្រមទាំងតាមដានស្ថានភាពសុខភាពស្ត្រីមានផ្ទៃពោះ ទារក និងកុមារទាំងនោះ
- ចលនា និងជំរុញលើកទឹកចិត្តស្ត្រីមានផ្ទៃពោះឱ្យទៅពិនិត្យផ្ទៃពោះជាទៀងទាត់មុនពេលសម្រាល ធ្វើការសម្រាលកូន និងពិនិត្យសុខភាពក្រោយពេលសម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ
- ចលនា និងជំរុញលើកទឹកចិត្តឳពុកម្តាយ ឬអ្នកអាណាព្យាបាល យកកូនទៅទទួលថ្នាំបង្ការ(រួមទាំងជីវជាតិបន្ថែម)ឱ្យបានគ្រប់ចំនួន និងតាមពេលវេលាកំណត់
- ផ្តល់ការកាគាំទ្រថវិកា និងមធ្យោបាយធ្វើដំណើរដល់ស្ត្រីក្រីក្រមានផ្ទៃពោះក្នុងការពិនិត្យផ្ទៃពោះមុនពេលសម្រាល ការសម្រាលកូននិងការពិនិត្យសុខភាពក្រោយពេលសម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ
- ផ្តល់ការគាំទ្រដល់កុមារស្គមស្គាំង ឬកុមារខ្វះអាហារូបត្ថម្ភ តាមរយៈការរៀបចំកម្មវិធីអាហារូបត្ថម្ភនានា
- គាំទ្រ និងដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ
- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជានៅក្នុងទិវាជាតិសុខភាពមាតា ទារក និងកុមារ ថ្ងៃទី២១ ខែកុម្ភៈ និងទិវាជាតិអាហារូបត្ថម្ភថ្ងៃទី០៦ ខែវិច្ឆិកា
- ចូលរួមអប់រំផ្សព្វផ្សាយអំពីសារៈសំខាន់នៃការថែទាំសុខភាពមាតានិងទារក ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ការពិនិត្យសុខភាពក្រោយពេលសម្រាល ការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ ការចាក់ថ្នាំបង្ការដល់កុមារឱ្យបានគ្រប់ចំនួន ការថែទាំសុខភាពបន្តពូជ និងកម្មវិធីសុខភាពផ្សេងៗទៀត ព្រមទាំងមូលរួមផ្សព្វផ្សាយអំពីព័ត៌មានពាក់ព័ន្ធនឹងបញ្ហាជំងឺឆ្លង បញ្ហាជំងឺមិនឆ្លង និងបញ្ហាសុខភាពសារណៈផ្សេងៗទៀត

**ខ)ការងារអត្តសញ្ញាណកម្ម**

- ចលនា និងជំរុញលើកទឹកចិត្តឳពុកម្តាយទារកទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើតឱ្យកូនរបស់ខ្លួននៅក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីកើត
- ចលនា និងជំរុញលើកទឹកចិត្ត យុវជន យុវនារី ទៅធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅពេលឈានចូលអាយុ១៥ឆ្នាំ
- ចលនា និងជំរុញលើកទឹកចិត្ត បុរស ស្ត្រី យុវជន យុវនារី ដែលបានសម្រេចរៀបអាពាហ៍ពិពាហ៍ទៅចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍

[6] ប្រការ ៧ នៃប្រកាស ៣៨៤០ ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

[7] ប្រការ ៨ នៃប្រកាស ៣៨៤០ ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

- ចលនា និងជំរុញលើកទឹកចិត្តគ្រួសារ ឬសាច់ញាតិរបស់មរណជនទៅចុះសៀវភៅអត្រានុកូលដ្ឋាន មរណភាព និងសំបុត្រមរណភាព ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃក្រោយថ្ងៃទទួលមរណភាព
- អប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីកាតព្វកិច្ច និងសារៈសំខាន់នៃការចុះអត្រានុកូលដ្ឋាន និងការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

**គ)ការងារសិក្សាអប់រំ**

- ចលនា និងជំរុញលើកទឹកចិត្តឪពុកម្តាយ ឬអ្នកអាណាព្យាបាលឱ្យបញ្ជូនកូនដែលមានអាយុ៣-៥ឆ្នាំចូលរៀនថ្នាក់មតេយ្យសិក្សា និងកូនដែលមានអាយុចាប់ពី៦ឆ្នាំ ឬយ៉ាងទាបបំផុតអាយុ៧០ខែឡើងទៅចូលរៀនថ្នាក់ទី១
- ចូលរួមអប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាលអំពីសារៈសំខាន់នៃការសិក្សាអប់រំរបស់ក្មេងស្រី ព្រមទាំងជំរុញលើកទឹកចិត្តដល់ក្មេងស្រីឱ្យបន្តការសិក្សានៅឧត្តមសិក្សា
- សម្របសម្រួលការរៀបចំបង្កើត និងដំណើរការមតេយ្យសិក្សាសហគមន៍
- តាមដានបញ្ហាអវត្តមានរបស់សិស្ស និងបញ្ហាផ្នែកអប់រំផ្សេងៗទៀត ព្រមទាំងសម្របសម្រួលដោះស្រាយបញ្ហាទាំងនេះតាមរយៈការជួបពិភាក្សាជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្ស និងលោកគ្រូអ្នកគ្រូ
- ចូលរួមរៀបចំទិវាជាតិអំណាន ថ្ងៃទី១១ ខែមិនា
- ចូលរួមផ្សព្វផ្សាយ និងលើកកម្ពស់ការអប់រំពហុភាសានៅតាមតំបន់ជនជាតិដើមភាគតិច
- ចូលរួមសម្របសម្រួលការអនុវត្តកម្មវិធីនានាពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការគាំពារដល់កុមារដូចជាកម្មវិធីទារកដ្ឋាន ការអប់រំឪពុកម្តាយ ឬអ្នកអាណាព្យាបាលអំពីរបៀបចិញ្ចឹមកូនតាមបែបវិជ្ជមានជាដើម។

**ឃ)ការទប់ស្កាត់អំពើហិង្សាទាក់ទងយេនឌ័រ ជាពិសេសអំពើហិង្សាលើស្ត្រីនិងកុមារ**

- កំណត់ និងស្រង់ទិន្នន័យជនងាយរងគ្រោះដោយសារអំពើហិង្សា(ផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្លូវសេដ្ឋកិច្ច) និងការបំពានខាងផ្លូវភេទ ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្មស្ត្រី និងកុមារនៅក្នុងឃុំ សង្កាត់
- ចូលរួមបង្ការ ទប់ស្កាត់ និងធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា និងការរំលោភបំពាននានាជាពិសេសទៅលើស្ត្រី និងកុមារ
- សម្របសម្រួលបញ្ជូនជនរងគ្រោះដោយអំពើហិង្សា ឬដោយការរំលោភបំពាននានាទៅទទួលសេវាសង្គ្រោះបន្ទាន់ ឬសេវាសមស្របនានា
- ចូលរួមអនុវត្តវិធានការដោះស្រាយ ឬវិធានការសមស្របនានាដើម្បីជួយដល់ជនរងគ្រោះដោយអំពើហិង្សា ឬដោយការរំលោភបំពាន រហូតដល់ជនរងគ្រោះទាំងនេះអាចរស់នៅបានប្រកបដោយសុវត្ថិភាព និងសុខុដុមរមនា
- តាមដាន កត់ត្រា និងរាយការណ៍អំពីករណីអំពើហិង្សា និងការរំលោភបំពាននានា។

**ង)ការងារកិច្ចការពារកុមារ**

- កំណត់ និងស្រង់ទិន្នន័យកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងឃុំ សង្កាត់
- ចូលរួមបង្ការ ទប់ស្កាត់ និងធ្វើអន្តរាគមន៍ចំពោះករណីអំពើហិង្សា ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពាននានាលើកុមារ

- សម្របសម្រួលបញ្ជូនកុមាររងគ្រោះដោយអំពើហិង្សានិងការរំលោភបំពាននានាទៅទទួលសេវាសមស្រប និងសេវាឯកទេស(ចិត្តសង្គម សុខភាព ផ្លូវច្បាប់)
- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជានៅក្នុងទិវាកុមារអន្តរជាតិថ្ងៃទី០១ មិថុនា
- ចូលរួមអនុវត្តវិធានការសមស្របនានា ដោយផ្អែកលើគោលការណ៍ឧត្តមប្រយោជន៍កុមារដើម្បីអភិវឌ្ឍ និងជួយដល់កុមាររងគ្រោះរហូតដល់កុមាររងគ្រោះទាំងនេះអាចរស់នៅប្រកបដោយសុវត្ថិភាព ព្រមទាំងទទួលបានការអប់រំមូលដ្ឋាន៩ឆ្នាំយ៉ាងតិចនិងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពជំនាញនានាសម្រាប់ការបំពេញការងារ។

**ច)ការងារទឹកស្អាត និងអនាម័យ**

- ចលនា និងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យប្រើប្រាស់ ឬបរិភោគទឹកដែលមានសុវត្ថិភាព
- ចលនា និងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋប្រើប្រាស់បង្គន់អនាម័យ លាងដៃនឹងសាប៊ូ និងប្រតិបត្តិជាប្រចាំនូវអនាម័យសំខាន់ៗផ្សេងៗទៀត
- ផ្តល់ការគាំទ្រដល់គ្រួសារដែលពុំមានលទ្ធភាពក្នុងការប្រើប្រាស់ទឹកដែលមានសុវត្ថិភាពនិងឬបង្គន់អនាម័យ
- ចូលរួមរៀបចំទិវាអនាម័យសំខាន់ៗដូចជាទិវាទឹកពិភពលោកថ្ងៃទី២២ ខែមីនា ទិវាពិភពលោកលាងដៃស្អាត់ ថ្ងៃទី១៥ ខែតុលា និងទិវាជាតិលើកកម្ពស់អនាម័យជនបទ ថ្ងៃទី១៣ ខែវិច្ឆិកាជាដើម

**ឆ)ការងារពិការភាព**

✓ ចលនា និងជំរុញលើកទឹកចិត្តដល់ជនមានពិការភាព និងគ្រួសារឱ្យចូលរួមក្នុងដំណើការកំណត់អត្តសញ្ញាណកម្មជនមានពិការភាព
✓ ស្រង់ស្ថិតិគ្រួសារដែលមានសមាជិកជាជនមានពិការភាព
✓ កំណត់បញ្ហា តម្រូវការ និងដោះស្រាយចាំបាច់នានារបស់ជនមានពិការភាព
✓ ចូលរួមអនុវត្តវិធានការសមស្របនានាដើម្បីឱ្យជនមានពិការភាពទទួលបាននូវព័ត៌មាន ចំណេះដឹងនិងសេវានានាប្រកបដោយសមធម៌សង្គម បរិយាបន្ន និងមានជីវភាពរស់នៅប្រកបដោយសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូរ
✓ ចូលរួមរៀបចំទិវាជនមានពិការភាពកម្ពុជា ថ្ងៃទី០៣ ខែធ្នូ។

**ជ)ការងារជនក្រីក្រ និងមនុស្សចាស់**

- ស្រង់ស្ថិតិគ្រួសារក្រីក្រ ឬចូលរួមកិច្ចដំណើការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ព្រមទាំងស្ថិតិមនុស្សចាស់ មនុស្សចាស់ក្រីក្រ
- កំណត់បញ្ហា តម្រូវការ និងដំណោះស្រាយនានារបស់ជនក្រីក្រ ជនចាស់ជរា និងមនុស្សចាស់ចូលរួមអនុវត្តវិធានការសមស្របនានាដើម្បីជួយដល់ជនក្រីក្រ ជនចាស់ជរា និងមនុស្សចាស់ក្នុងការទទួលបាននូវជីវភាពរបស់នៅប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ
- ចូលរួមសម្របសម្រួលនិងគាំទ្រការរៀបចំបង្កើតនិងដំណើរការរបស់សមាគមមនុស្សចាស់នៅតាមសហគមន៍
- ចូលរួមរៀបចំទិវាមនុស្សចាស់កម្ពុជា ថ្ងៃទី០១ ខែតុលា

**ឈ)ការបង្ការទប់ស្កាត់ប្រើប្រាស់គ្រឿងញៀន(រួមទាំងគ្រឿងស្រវឹង)**

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋជាពិសេសយុវជនអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀននិងគ្រឿងស្រវឹង
- ចូលរួមកំណត់មុខសញ្ញាអ្នកចរាចរ និងឬអ្នកប្រើប្រាស់គ្រឿងញៀន

- ចូលរួមអនុវត្តវិធានការសមស្របនានា ដើម្បីបង្កា និងទប់ស្កាត់ការចរាចរ និងការប្រើប្រាស់គ្រឿងញៀន ព្រមទាំងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

**៣)ការលើកកម្ពស់សមភាពយេនឌ័រ**

- ចលនា និងជំរុញលើកទឹកចិត្តស្ត្រីឱ្យចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់
- ចលនា និងជំរុញលើកទឹកចិត្តស្ត្រីឱ្យចូលរួមសកម្មភាពនយោបាយ និងអភិវឌ្ឍន៍សេដ្ឋកិច្ចដើម្បីលើកកម្ពស់ឋានៈស្ត្រីនៅក្នុងគ្រួសារ និងសង្គមជាតិ
- ចូលរួមអនុវត្តវិធានការសមស្របនានាដើម្បីផ្តល់ភាពអង់អាចដល់ស្ត្រី និងលើកកម្ពស់សមធម៌សង្គម និងបរិយាបន្ន
- ចូលរួមផ្សព្វផ្សាយអំពីការផ្លាស់ប្តូឥរិយាបថ និងផ្នត់គំនិតអវិជ្ជមានដែលរារាំងដល់ស្ត្រី និងក្មេងស្រីក្នុងការចូលរួមការងារសង្គម និងសហគមន៍
- ចូលរួមផ្សព្វផ្សាយសារលិខិតរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជានៅក្នុងទិវានារីអន្តរជាតិថ្ងៃទី០៨ ខែមីនា។

**ឃ)ការងារសេវាសង្គមផ្សេងៗទៀត។**

- សម្របសម្រួល និងអនុវត្តសកម្មភាពសេវាសង្គមផ្សេងៗទៀតដែលបានប្រគល់ឱ្យរដ្ឋបាលឃុំ សង្កាត់។

ទន្ទឹមនឹងអនុវត្តមុខងារចម្បងខាងលើ គ.ក.ន.ក ចូលរួមអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពដែលចាប់ផ្តើមអនុវត្តតាំងពីឆ្នាំ២០១០ កន្លងមកគឺជាយន្តការមួយដើម្បីកាត់បន្ថយបទល្មើសនៅថ្នាក់មូលដ្ឋាននៅទូទាំងប្រទេសរួមមានអំពើចោរកម្មជាអាទិ៍លួចឆក់ ប្លន់ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស គ្រឿងញៀន ល្បែងស៊ីសងសកម្មភាពទំនើង និងការប្រើប្រាស់អាវុធខុសច្បាស់ជាដើម ។ល។ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព៖

- គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរការចែកចាយ និងការប្រើប្រាស់គ្រោះងញៀនខុសច្បាប់
- គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- មានវិធានការការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់។

គ.ក.ន.ក ចូលរួមអនុវត្តសេចក្តីសម្រេចលេខ១៩៥៦ សសរ ចុះថ្ងៃទីចុះថ្ងៃទី២ ឧសភា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំសង្កាត់។ សៀវភៅណែនាំនេះបានបញ្ជាក់ពីបញ្ហាសេវាសង្គមមួយចំនួននៅឃុំ សង្កាត់មានដូចជាសុខភាពមាតា ទារក និងអាហារូបត្ថម្ភ អនាម័យ និងទឹកស្អាត កិច្ចការពារកុមារ ការអប់រំកុមារតូច និងភាពងាយរងគ្រោះជាដើម។ បញ្ហាទាំងនោះសុទ្ធសឹងជាអាទិភាពតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សា ឃុំ សង្កាត់ និង គ.ក.ន.ក បង្កើនការយកចិត្តទុកដាក់ក្នុងការផ្តល់សេវាសង្គមឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងសមធម៌។

តារាងទី២៖សូចនាករសេវាសង្គមដែលឃុំ សង្កាត់យកចិត្តទុកដាក់

| ល.រ | សូចនាករ | បញ្ហាសេវាសង្គម |
|---|---|---|
| ១ | ខ្នងផ្ទះស្ត្រីមានផ្ទៃពោះមិនបានទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល | បញ្ហាសុខភាព មាតា ទារក និង អាហារូបត្ថម្ភ |
| ២ | ខ្នងផ្ទះស្ត្រីមានផ្ទៃពោះមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាល | |
| ៣ | ខ្នងផ្ទះមានកុមារអាយុ ១២-២៣ខែដែលមិនបានចាក់ថ្នាំបង្ការគ្រប់ | |
| ៤ | ខ្នងផ្ទះមានកុមារស្គមស្គាំងនៅអាយុក្រោម៥ឆ្នាំ | |
| ៥ | ខ្នងផ្ទះគ្មានបង្គន់អនាម័យប្រើប្រាស់ | បញ្ហាទឹក និង អនាម័យ |
| ៦ | ខ្នងផ្ទះមិនបរិភោគទឹកមានសុវត្ថិភាព | |
| ៧ | ខ្នងផ្ទះដែលមានកុមារធ្លាប់ទទួលរងអំពើហិង្សា | បញ្ហាកិច្ចការពារកុមារ |
| ៨ | ខ្នងផ្ទះមានកុមារងាយរងគ្រោះចំពោះការបំបែកចេញពីគ្រួសារ | |
| ៩ | ខ្នងផ្ទះមានកុមារវិលត្រលប់មកពីមណ្ឌលកុមារកំព្រារស់នៅជាមួយ | |
| ១០ | ខ្នងផ្ទះមានសមាជិកគ្រួសារដែលគ្មានសំបុត្រកំណើត ឬបញ្ជាក់កំណើត | |
| ១១ | ខ្នងផ្ទះមានកុមារអាយុ៣-៥ឆ្នាំមិនបានទទួលការអប់រំគ្រប់ទម្រង់នៃការអប់រំកុមារតូច | បញ្ហាការអប់រំកុមារតូច |
| ១២ | ខ្នងផ្ទះមានកុមាររៀននៅបឋមសិក្សា ហើយអាណាព្យាបាលមិនដែល បានជួនជាមួយតំណាងសាលា ឬគ្រូ | |
| ១៣ | ខ្នងផ្ទះមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ(ប័ណ្ណក្រីក្រ)មានសុពលភាព | បញ្ហាភាពងាយរងគ្រោះ |
| ១៤ | ខ្នងផ្ទះមានសមាជិកមានពិការភាព | |

រូបភាពទី៤៖ គំរូផែនទីសេវាសង្គមសម្រាប់ភូមិនីមួយៗ



## ៣. សកម្មភាពមានកំណត់នៅក្នុងគោលនយោបាយ

## ៣.១. ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥

### ៣.១.១.ប្រព័ន្ធជំនួយសង្គម

**កម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម៥ឆ្នាំ**

- សិក្សា និងវាយតម្លៃអំពីម៉ូដែលនៃការដាក់ឱ្យអនុវត្តកម្មវិធីលើកកម្ពស់អាហារូបត្ថម្ភ រួមបញ្ចូលទាំងការអនុវត្តសាកល្បងដើម្បីកំណត់អំពីម៉ូដែលណាមួយដែលមានប្រសិទ្ធភាព និងសមស្របសម្រាប់កម្ពុជា
- កំណត់អំពីស្ថាប័នអនុវត្ត និងកំណត់ឱ្យបានច្បាស់អំពីតួនាទី និងភារកិច្ច
- ធ្វើការកំណត់អំពីខេត្តគោលដៅដែលត្រូវដាក់ឱ្យអនុវត្តមុន ដោយផ្អែកលើភាពងាយរងគ្រោះនិងតម្រូវការ
- រៀបចំយន្តការការងារ និងការកសាងសមត្ថភាព
- ពង្រីកវិសាលភាពគ្របដណ្តប់ថ្នាក់ជាតិ ព្រមទាំងធ្វើការកែសម្រួលឱ្យកាន់តែមានប្រសិទ្ធភាព និងសក្តិសិទ្ធភាព
- ពង្រីកការអនុវត្តគ្របដណ្តប់ថ្នាក់ជាតិដោយពឹងផ្អែកលើការវិភាគអំពីតម្រូវការ និងគោលដៅអាទិភាពលើតំបន់ភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម និងកត្តាសមធម៌ដទៃទៀត
- ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត
- បង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃដើម្បីវាស់ស្ទង់វឌ្ឍនភាព និងសិក្សាលើផលប៉ះពាល់ជាមួយនិងការសម្រេចចិត្តប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា
- ដាក់ឱ្យអនុវត្តកម្មវិធីលើកកម្ពស់អាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម៥ឆ្នាំ នៅក្នុងខេត្តអាទិភាព
- សិក្សាលើយន្តការផ្តល់ការត្រួតពិនិត្យផ្ទៃពោះ
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្ត
- ធ្វើការកែសម្រួលដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងសក្តិសិទ្ធិភាព

**កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនពិការ**

- រៀបចំសេចក្តីណែនាំសម្រាប់ការអនុវត្តអនុក្រឹត្យស្តីពីប្រាក់ឧបត្ថម្ភសម្រាប់ជនពិការ
- រៀបចំរចនាសម្ព័ន្ធស្ថាប័នដើម្បីគ្រប់គ្រង និងចាត់ចែងកម្មវិធីនេះឱ្យមានប្រសិទ្ធភាពខ្ពស់
- អនុវត្តអនុក្រឹត្យស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ជនពិការនៅក្នុងខេត្តគោលដៅ
- ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្ត និងលទ្ធផលនៅក្នុងខេត្តគោលដៅ
- សិក្សាអំពីលទ្ធភាពក្នុងការពង្រីកវិសាលភាពនៃការអនុវត្តទៅកាន់ខេត្តផ្សេងៗទៀត
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត និងលទ្ធផល
- ធ្វើការកែសម្រួលដើម្បីការអនុវត្តប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព

**កម្មវិធីគាំពារជនចាស់ជរា**

- កំណត់លក្ខណៈវិនិច្ឆ័យអ្នកទទួលផល និងកម្រិតអត្ថប្រយោជន៍
- សិក្សាពីលទ្ធភាពសម្រាប់កំណត់អត្តសញ្ញាណអ្នកទទួលផល និងស្ថាប័នអនុវត្ត
- រៀបចំ និងអភិវឌ្ឍសមត្ថភាពស្ថាប័ន
- កំណត់ខេត្តគោលដៅ
- សិក្សាការដាក់ឱ្យដំណើរការកម្មវិធីនេះជាកញ្ចប់គ្រួសាររួមជាមួយកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះនិងកុមារ

- សិក្សាការដាក់ឱ្យអនុវត្តកម្មវិធីគាំពារជនចាស់ជរានៅក្នុងខេត្តអាទិភាព
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត និងលទ្ធផល
- រៀបចំផែនការដើម្បីពង្រីកវិសាលភាពក្នុងការគ្រប់ដណ្តប់ទូទាំងប្រទេស
- ដាក់ឱ្យអនុវត្តកម្មវិធីទូទាំងប្រទេស
- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត

**៣.១.២.ប្រព័ន្ធសន្តិសុខសង្គម**

យន្តការបណ្តោះអាសន្នដើម្បីកាត់បន្ថយគម្លាតនៃរបបសោធនរបស់មន្ត្រីសាធារណៈ

- រៀបចំសេចក្តីសម្រេច/ណែនាំដើម្បីបញ្ជាក់ឡើងវិញអំពីការកំណត់របបប្រាក់សោធនសម្រាប់មន្ត្រីនគរបាលជាតិ និងយោធិននៃកងយោធពលខេមរភូមិន្ទ

របបសោធនសម្រាប់មន្ត្រីសាធារណៈ

- កែសម្រួលព្រះរាជក្រឹត្យស្តីពីការបង្កើត ប.ជ.ស និង ប.ជ.អ ដើម្បីធ្វើឯកភាពរូបនីយកម្ម ប.ជ.ស និង ប.ជ.អ ឱ្យទៅជាស្ថាប័នតែមួយ និងពង្រីកវិសាលភាពឱ្យគ្របដណ្តប់មន្ត្រីសាធារណៈផ្សេង
- រៀបចំយន្តការវិនិយោគមូលនិធិ
- សិក្សាវាយតម្លៃអំពីហានិភ័យ
- សិក្សាវាយតម្លៃអំពីហានិភ័យ

## ៣.២. គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (៧.២.២០)

- សហការជាមួយក្រសួង និងស្ថានប័នពាក់ព័ន្ធនានាក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់
- បញ្ជ្រាប បណ្តុះបណ្តាល និងបំពាក់បរិក្ខារតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យនៅទីជនបទ និងតំបន់ទីប្រជុំជន អំពីការផ្តល់សេវាថែទាំសុខភាពមនុស្សចាស់
- លើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការស្ម័គ្រចិត្តនានាដើម្បីបង្កើតនិងព្រីកឱកាសផ្សេងៗ ទាំងផ្លូវការ ទាំងមិនមែនផ្លូវការ ដែលធ្វើឱ្យមនុស្សចាស់អាចពឹងផ្អែកខ្លួនឯងបានផ្នែកសេដ្ឋកិច្ច
- ស្វែងយល់ពីលទ្ធភាពផ្តល់អត្ថប្រយោជន៍ពន្ធ ជាការលើកទឹកចិត្តដល់បុត្រធីតាដែលមើលថែទាំឪពុកម្តាយរបស់ពួកគេ
- គិតគូរពិចារណាពីលទ្ធភាពនៃការផ្តល់របបសន្តិសុខសង្គម ដល់ជនក្រីក្រជាមនុស្សចាស់ និងប្រាក់សោធននិវត្តដល់អ្នកមេម៉ាយ ពោះម៉ាយ

## ៣.៣. គោលនយោបាយជាតិប្រជាជន ២០១៧-២០៣០

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (៦.២.១៣)

- សហការជាមួយក្រសួង និងស្ថានប័នពាក់ព័ន្ធនានាក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិប្រជាជន
- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយជាតិឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងកម្មវិធីអំពីមនុស្សចាស់ តាមផែនការសកម្មភាពទីក្រុងម៉ាឌ្រីដឆ្នាំ២០០២ និងឆ្លើយតបទៅនឹងតម្រូវការ និងកំណើនប្រជាជនជាក់ស្តែងនាពេលបច្ចុប្បន្ន និងអនាគត

- បញ្ជ្រាប បណ្តុះបណ្តាល និងបំពាក់បរិក្ខារតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យនៅទីជនបទ និងតំបន់ទីប្រជុំជន អំពីការផ្តល់សេវាថែទាំសុខភាពមនុស្សចាស់
- លើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការស្ម័គ្រចិត្តនានាដើម្បីបង្កើតនិងពង្រីកឱកាសផ្សេងៗ ទាំងផ្លូវការ ទាំងមិនមែនផ្លូវការ ដែលធ្វើឱ្យមនុស្សចាស់អាចពឹងផ្អែកខ្លួនឯងបានផ្នែកសេដ្ឋកិច្ច
- ស្វែងយល់ពីលទ្ធភាពផ្តល់អត្ថប្រយោជន៍ពន្ធ ជាការលើកទឹកចិត្តដល់បុត្រធីតាដែលមើលថែទាំឪពុកម្តាយរបស់ពួកគេ
- គិតគូរពិចារណាពីលទ្ធភាពនៃការផ្តល់របបសន្តិសុខសង្គម ដល់ជនក្រីក្រជាមនុស្សចាស់ និងប្រាក់សោធននិវត្តដល់អ្នកមេម៉ាយ ពោះម៉ាយ
- ចាំបាច់ត្រូវគិតគូរពិចារណាផ្សារភ្ជាប់ជាមួយនឹងការបង្កើតជំនាញដល់យុវជន ជាពិសេសអ្នកនៅក្រៅសាលា និងអ្នកឈប់ប្រើប្រាស់សារជាតុញៀន

## ៣.៤. គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ២០០៦

### ៣.៤.១.ការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល

- ពិនិត្យឡើងវិញ ការរៀបចំបង្កើតគោលនយោបាយ ច្បាប់ និងចងក្រងលិខិតបទដ្ឋានផ្សេងៗទៀតឱ្យស្របទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីប្រកាសទីក្រុងស្តុកខុលស្តីពីកុមារ និងការថែទាំតាមមណ្ឌលស្នាក់នៅយូរអង្វែង សេចក្តីប្រកាសស្តីពីគោលការណ៍សង្គម និងច្បាប់នានាដែលទាក់ទងទៅនឹងកិច្ចការពារនិងសុខុមាលភាពរបស់កុមារ ហើយដែលមានខ្លឹមសារពិសេសពាក់ព័ន្ធទៅនឹងការរៀបចំកុមារឱ្យគេចិញ្ចឹមជាកូនធម៌ និងជាកូនចិញ្ចឹមក្នុងប្រទេស និងក្រៅប្រទេស គោលការណ៍សហប្រជាជាតិសម្រាប់ការពារអនីតិជនដែលត្រូវបានគេដកហូតសេរីភាព និងលិខិតតូបករណ៍ច្បាប់អន្តរជាតិពាក់ព័ន្ធនានា
- ផ្សព្វផ្សាយ និងធានាការអនុវត្តគោលនយោបាយ ច្បាប់ និងឯកសារពាក់ព័ន្ធឯទៀតឱ្យមានប្រសិទ្ធភាព
- ដឹកនាំការបង្កើត និងអនុម័តបទដ្ឋានអប្បបរិមា និងគោលការណ៍ណែនាំស្តីពីការថែទាំជំនួស
- ផ្អែកតាមការអនុវត្តន៍បទដ្ឋានអប្បបរិមា និងគោលការណ៍ណែនាំជាធរមាន ពិនិត្យ តាមដានវាយតម្លៃ និងផ្តល់ការអនុញ្ញាតដល់អ្នកផ្តល់សេវាថែទាំជំនួសរបស់រដ្ឋ និងរបស់អង្គការមិនមែនរដ្ឋាភិបាលនានា
- បែងចែកថវិកាសម្រាប់ឧបត្ថម្ភដល់ការងារថែទាំជំនួសស្របតាមចំនួនអ្នកទទួលផល គោលនយោបាយជាតិបទដ្ឋានអប្បបរិមា និងគោលការណ៍ណែនាំដោយផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើតួនាទីរបស់មន្ត្រីរាជការក្នុងការប្រតិបត្តិ ពិនិត្យ តាមដាន និងវាយតម្លៃកម្មវិធីថែទាំជំនួស
- បង្កលក្ខណៈងាយស្រួលជួយភ្នាក់ងារផ្តល់សេវាថែទាំជំនួសរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការកៀរថវិកា និងជួយរកដំណោះស្រាយ និងការអនុវត្តន៍ប្រកបដោយនិរន្តភាព
- ដឹកនាំសម្របសម្រួល និងផ្តល់កិច្ចសហប្រតិបត្តិការដល់ដៃគូផ្តល់ជំនួយ

### ៣.៤.២.ការប្តេជ្ញាចិត្តរបស់មន្ត្រី និងភ្នាក់ងារផ្តល់ការថែទាំជំនួស

- សហការជាមួយស្ថាប័នមានកិច្ចរបស់រាជរដ្ឋាភិបាលជួយពិនិត្យឡើងវិញ ការរៀបចំ និងផ្សព្វផ្សាយគោលនយោបាយ ច្បាប់ បទដ្ឋានអប្បបរិមា និងគោលការណ៍ស្តីពីការថែទាំជំនួសឱ្យស្របទៅតាម អនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីប្រកាសទីក្រុងស្តុកខុលស្តីពីកុមារ និងការថែទាំតាមមណ្ឌលស្នាក់នៅយូរអង្វែងហើយនិងគោលការណ៍នានារបស់អនុសញ្ញា និងសេចក្តីប្រកាស
- អនុវត្តគោលនយោបាយ ច្បាប់ បទដ្ឋានអប្បបរមា និងគោលការណ៍ណែនាំស្តីពីការថែទាំជំនួស

- ពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងារផ្ទាល់ ផ្តល់របាយការណ៍ ព្រមទាំងជួយសម្រួលដល់ការពិនិត្យ តាមដាន និងវាយតម្លៃដោយក្រសួង ស.អ.យ ឱ្យសមស្របទៅតាមគោលនយោបាយ បទដ្ឋានអប្បបរមា និងគោលការណ៍ណែនាំស្តីពីការថែទាំជំនួស
- សុំការអនុញ្ញាត និងចុះកិច្ចព្រមព្រៀងជាមួយក្រសួង ស.អ.យ
- កៀគរកថវិកាឱ្យបានគ្រប់គ្រាន់សម្រាប់ឧបត្ថម្ភអ្នកទទួលផល និងបែងចែកថវិកាឧបត្ថម្ភដល់កម្មវិធីនានាឱ្យស្របទៅតាម គោលនយោបាយជាតិ បទដ្ឋានអប្បបរមា និងគោលការណ៍ណែនាំ
- ជួយអភិវឌ្ឍ និងអនុវត្តដំណោះស្រាយប្រកបដោយនិរន្តរភាពដោយយកចិត្តទុកដាក់ពិសេសទៅលើការលើកស្ទួយដំណោះស្រាយនានាទៅតាមគ្រួសារ និងសហគមន៍
- ជួយលើស្ទួយគោលការណ៍ស្តីពីការថែទាំជំនួស តាមរយៈគោលនយោបាយសម្រាប់បុគ្គលិក (តួនាទី ការទទួលខុសត្រូវ ការជ្រើសបុគ្គលិក ការបណ្តុះបណ្តាល បៀវត្សរ៍ និងការគ្រប់គ្រង) និងគោលនយោបាយទាក់ទងដល់ការទទួលយកកុមារមកចិញ្ចឹមថែទាំ(ក្រុមគោលដៅ លក្ខណៈវិនិច្ឆ័យ និងនីតិវិធីផ្សេងៗ)។

## ៣.៥. គោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩

គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ[៨] បានកំណត់នូវសសរស្តម្ភជាយុទ្ធសាស្រ្តសំខាន់ៗចំនួន៣ ដោយផ្តោតទៅលើការបង្ការនិងទប់ស្កាត់ ការអន្តរាគម និងការផ្តល់សេវាឆ្លើយតប ជាមួយគ្នានេះដែរក៏បានកំណត់នូវសកម្មភាពជាក់លាក់សម្រាប់ក្រសួងស្ថាប័នដែលបំពេញការងារ បង្ការទប់ស្កាត់ ការអន្តរាគម ការផ្តល់សេវាឆ្លើយតប ជាពហុវិស័យទាន់ពេលវេលាចំពោះកុមារគ្រប់រូប ដោយគ្មានការរើសអើង និងត្រូវឱ្យមានភាពប្រទាក់ក្រឡានិងស៊ីចង្វាក់គ្នា ចាប់ពីវិធានការបង្ការទប់ស្កាត់រហូតដល់ការឆ្លើយតបចំពោះកុមាររងគ្រោះ ឱ្យទទួលបានសុវត្ថិភាព ទាំងផ្លូវកាយ ផ្លូវចិត្ត និងសុខុមាលភាព។ ដើម្បីផ្តល់សេវាកិច្ចការពារកុមារ និងជំរុញឱ្យមានផ្លាស់ប្តូរឥរិយាបថសង្គមចំពោះការប្រព្រឹត្តទៅលើកុមារគឺទាមទារឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានធនធានមនុស្សនិងថវិកាគ្រប់គ្រាន់។

### ៣.៥.១.ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ

ប្រព័ន្ធអប់រំ៖ **ក្រសួងអប់រំ យុវជន និងកីឡា**

ប្រព័ន្ធផ្សព្វផ្សាយ៖ **ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងសភាពាណិជ្ជកម្មកម្ពុជា**

វិស័យសាសនានិងទំនៀមទម្លាប់ជនជាតិដើមភាគតិច៖ **ក្រសួងធម្មការនិងសាសនា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

យន្តការនៅថ្នាក់សហគមន៍ទាក់ទងនឹងស្ត្រីនិងកុមារ៖ **អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ**

ប្រព័ន្ធសុខុមាលភាពគ្រួសារនិងការចិញ្ចឹមកូនតាមបែបវិជ្ជមាន៖ **ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី**

---

[៨] គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩ អនុម័តដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០

រូបភាពទី៥.ការបង្ការទប់ស្កាត់ក្នុងកិច្ចការពារកុមារ




### ៣.៥.២.ប្រព័ន្ធអន្តរាគមន៍

យន្តការតុលាការ៖ **ក្រសួងយុត្តិធម៌ សាលាវិជ្ជាជីវៈតុលាការ**
យន្តការនគរបាលយុត្តធម៌៖ **អគ្គស្នងការនគរបាលជាតិ បណ្ឌិត្យសភានគរបាលកម្ពុជា កងរាជអាវុធហត្ថលើផ្ទៃប្រទេស**
យន្តការនៅថ្នាក់សហគមន៍ទាក់ទងនឹងស្ត្រីនិងកុមារ៖ **នាយកដ្ឋានអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃក្រសួងមហាផ្ទៃ**

រូបភាពទី៦.ប្រព័ន្ធអន្តរាគមន៍




### ៣.៥.៣.ប្រព័ន្ធឆ្លើយតបនិងផ្តល់សេវា

ប្រព័ន្ធសុខុមាលភាពកុមារនិងគ្រួសារ៖**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
ប្រព័ន្ធអប់រំ៖**ក្រសួងអប់រំ យុវជន និងកីឡា**
ប្រព័ន្ធសុខាភិបាល៖**ក្រសួងសុខាភិបាល**
ប្រព័ន្ធគាំពារសង្គម៖**ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សភាពាណិជ្ជកម្មកម្ពុជា**
ប្រព័ន្ធរាយការណ៍៖**ក្រសួងមហាផ្ទៃ និងអគ្គស្នងការនគរបាលជាតិ**
ប្រព័ន្ធទូរស័ព្ទជំនួយ៖**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
យន្តការភ្នាក់ងារផ្តល់សេវាសង្គមកិច្ច៖**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី**
យន្តការផ្តល់សេវាផ្នែកច្បាប់៖**ក្រសួងយុត្តិធម៌ និងគណៈមេធាវីកម្ពុជា**
យន្តការឆ្លើយតបគ្រោះមហន្តរាយ៖**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ កាកបាទក្រហមកម្ពុជា**

រូបភាពទី៧.ប្រព័ន្ធផ្តល់សេវាឆ្លើយតប




ប្រព័ន្ធកិច្ចការពារកុមារ គឺជាបណ្តុំនៃវិធានបង្កើតឡើងក្នុងគោលបំណងជំរុញនិងលើកកម្ពស់ការការពារកុមារពីការរំលោភបំពាននិងការកេងប្រវ័ញ្ចគ្រប់ទម្រង់។ វិធានទាំងនេះរួមមាន៖១.ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ២.ការផ្តល់ជំនួយនិងសេវា ៣.ធនធានមនុស្សនិងហិរញ្ញវត្ថុ និង៤.ការផ្លាស់ប្តូរឥរិយាបថសង្គមក្នុងការប្រព្រឹត្តទៅលើកុមារដែលវិធានទាំងនេះត្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាពិសេសវិស័យសុខុមាលភាពសង្គម អប់រំ សុខភាព សន្តិសុខ និងយុត្តិធម៌ ក្នុងការគាំទ្រដល់ការបង្ការទប់ស្កាត់និងឆ្លើយតបទៅនឹងហានិភ័យផ្សេងៗ។

រូបភាពទី៨៖ បណ្តុំនៃវិធានការកិច្ចការពារកុមារ




## ៤. សកម្មភាពមានកំណត់នៅក្នុងច្បាប់

### ៤.១. ច្បាប់យុត្តិធម៌អនីតិជន

- ការតែងតាំង ការទទួលស្គាល់ និងគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច
- បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ចត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលមន្ទុកវិស័យសង្គមកិច្ច

- ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍៖
    - ជួបអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធីជាពិសេសនៅដំណាក់កាលដំពុងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន
    - ប្រមូលព័ត៌មានស្តីពីស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តិអប់រំ ការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការស់នៅ ការរីកលូតលាស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងកម្រិតយល់ដឹង បញ្ហាអារម្មណ៍ ផ្លូវចិត្តសង្គមរបស់អនីតិជន ដើម្បីរៀបចំផ្តល់របាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រម អយ្យការ និងតុលាការ
    - ផ្តល់ការគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី
    - រៀបចំ និងផ្តល់ផែនការបង្វែរជូនអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យ និងសម្រេច
    - ផ្តល់សេវាស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជន
    - ភារកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស.អ.យ
- ត្រូវបង្កើតឱ្យមានមណ្ឌលយុវនីតិសម្បទានៅតាមរាជធានីខេត្ត សម្រាប់គ្រប់គ្រងអនីតិជន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទាត្រូវកំណត់ដោយអនុក្រឹត្យ។
- ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាត្រូវបែងចែកជា ៣(បី) ផ្នែកដាច់ដោយឡែកពីគ្នា៖
    - ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន
    - ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា
    - ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជនដើម្បីទទួលកម្មវិធីសមាហរណកម្ម
- បែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដែលត្រូវជាប់ឃុំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។
- គ្រប់មណ្ឌលយុវនីតិសម្បទាត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជនព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាឱ្យមានសុវត្ថិភាព។ បញ្ជី និងនីតិវិធីដោយឡែកនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ៤.២. ច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន

### ៤.២.១.វិធាននៃការគ្រប់គ្រងការព្យាបាល និងស្តារនីតិសម្បទា

- ការព្យាបាល និងការស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន ត្រូវមានសេវាផ្នែកវេជ្ជសាស្ត្រ និងសេវាសង្គមកិច្ចសមស្របតាមបែបវិទ្យាសាស្ត្រ ជាអាទិ៍៖
    - ការព្យាបាល និងការស្តារនីតិសម្បទាត្រូវគ្រប់គ្រងដោយអ្នកជំនាញផ្នែកថែទាំសុខភាព និងអ្នកជំនាញផ្នែកស្តារនីតិសម្បទា

- វិធីសាស្ត្រព្យាបាល និងស្តារនីតិសម្បទាត្រូវច្បាស់លាស់ចំពោះសេចក្តីត្រូវការតាមរោគសញ្ញារបស់បុគ្គលម្នាក់ៗ ហើយត្រូវបានសម្រេចដោយអ្នកជំនាញផ្នែកថែទាំសុខភាព និងអ្នកជំនាញផ្នែកស្តារនីតិសម្បទាដោយមានពិគ្រោះយោបល់ និងយល់ព្រមពីបុគ្គលនោះ
- ការព្យាបាល និងការស្តារនីតិសម្បទានោះត្រូវស្របទៅតាមនិយាមជាតិ និងអន្តរជាតិ ហើយប្រតិបត្តិឱ្យបានល្អបំផុត ទៅលើវិធានការព្យាបាលភាពញៀនគ្រឿងញៀនឱ្យមានប្រសិទ្ធភាព និងមនុស្សធម៌
- ការព្យាបាល និងការស្តារនីតិសម្បទានោះត្រូវគ្រប់គ្រងក្នុងផលប្រយោជន៍តែមួយគត់សម្រាប់អ្នកញៀនគ្រឿងញៀន ដើម្បីធ្វើឱ្យពួកគេទទួលបានសមត្ថភាពតាមផ្លូវច្បាប់យ៉ាងពេញលេញ។
- វិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលសាធារណៈសម្រាប់ព្យាបាល និងស្តារនីតិសម្បទារបស់រដ្ឋ មានរយៈពេលចាប់ពី ៦ខែ ដល់ ២ឆ្នាំ

- នីតិវិធីលម្អិតសម្រាប់វិធីសាស្ត្រព្យាបាល និងការគ្រប់គ្រងវិធានការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀនត្រូវកំណត់ដោយអនុក្រឹត្យ
- ក្នុងគ្រប់ករណីទាំងអស់គ្មានបុគ្គលណាម្នាក់ដែលស្ថិតនៅក្រោមការព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន ជាកម្មវត្ថុនៃការពិសោធផ្នែកវេជ្ជសាស្ត្របានឡើយ

### ៤.២.២.ការព្យាបាល និងស្តារនីតិសម្បទា

- ការព្យាបាល និងការស្តារនីតិសម្បទាដោយស្ម័គ្រចិត្ត។ មុននឹងសម្រេចចិត្តទទួលយកការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនមានសិទ្ធិទទួលបានពីមជ្ឈមណ្ឌលនូវព័ត៌មានសំខាន់ៗអំពីការព្យាបាល និងការស្តារនីតិសម្បទាជាអាទិ៍៖
  - ប្រភេទ និងរយៈពេលនៃការព្យាបាល និងការស្តារនីតិសម្បទា
  - វិធីការព្យាបាល និងស្តារនីតិសម្បទា និងការលំបាកនៃការព្យាបាល និងការស្តារនីតិសម្បទា
  - ផលប្រយោជន៍នៃការព្យាបាល និងស្តារនីតិសម្បទាដែលរំពឹងទុក
  - ផលប៉ះពាល់ជាយថាហេតុដោយសារការព្យាបាល និងការស្តានីតិសម្បទា
  - ជម្រើសផ្សេងទៀតក្រៅពីការព្យាបាល និងការស្តារនីតិសម្បទា ប្រសិនបើមាន
  - ផលវិបាកនៃការមិនទទួលយកការព្យាបាល និងការស្តារនីតិសម្បទា
- ការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំ
- មជ្ឈមណ្ឌលឯកជន និងសហគមន៍ ព្យាបាល និងស្តារនីតិសម្បទាត្រូវមានការទទួលស្គាល់ពីក្រសួងសុខាភិបាល និងក្រសួង ស.អ.យ

## ៤.៣. ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

❖ **ក្រុមប្រឹក្សាសកម្មភាពជនពិការ និងរដ្ឋបាលសិទ្ធិជនពិការ**

មាត្រា ៥ ត្រូវបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាពិការភាព។ មាត្រា ៦ ក្រុមប្រឹក្សាសកម្មភាពជនពិការមានភារកិច្ច៖

- ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងស្តាលទ្ធភាពពលកម្ម
- ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងស្តារលទ្ធភាពពលកម្ម

- ជម្រុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម
- លើកសំណើកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្ម គោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម
- តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព
- ទំនាក់ទំនងជាសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុង និងក្រៅប្រទេស។

មាត្រា ៨ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវបង្កើតរដ្ឋបាលសិទ្ធជនពិការដែលជាអង្គភាពចំណុះនាយកដ្ឋានស្តារលទ្ធភាពពលកម្ម។

- មាត្រា ៤៦ ត្រូវបង្កើត**មូលនិធិជនពិការ** ជាគ្រឹះស្ថានរដ្ឋបាលសាធារណៈក្នុងគោលបំណងដូចតទៅ៖ (បង្កើតដោយអនុក្រឹត្យ)

  ១. ផ្តល់មូលនិធិសម្រាប់ការអនុវត្តគម្រោងកម្មវិធីផ្សេងៗដែលជួយដល់ជនពិការ និងគាំទ្រដល់ស្ថាប័ន គ្រឹះស្ថាននានា ដែលផ្តល់សេវាកម្មដល់ជនពិការដូចជាផ្នែកសុខាភិបាល ស្តារលទ្ធភាពពលកម្ម អប់រំបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងការរកការងារឱ្យធ្វើ។

  ២. លើកកម្ពស់ និងបង្កើនសុខុមាលភាពរបស់ជនពិការជាពិសេសៈ
    - ជនពិការក្រីក្រ និងយោធិនពិការ ដែលបានទទួលសេវាស្តារលទ្ធភាពពលកម្ម
    - គ្រួសារជនពិការក្រីក្រ និងយោធិនពិការ ដែលពឹងផ្អែកលើជនពិការក្នុងជីវភាពរស់នៅ
    - ជនពិការក្រីក្រ និងយោធិនពិការ ដែលបានទទួលសេវាស្តាលទ្ធភាពពលកម្ម ឬជនពិការ ដែលមានជំនាញតែពុំទាន់ទទួលបានការងារធ្វើ។

  ៣. ផ្តល់ប្រាក់កម្ចីសម្រាប់ការសម្របសម្រួលសមស្រប

- រៀបចំកម្មវិធីស្តារកាយសម្បទា និងសតិបញ្ញា ជួយដល់ជនពិការឱ្យអាចបំពេញមុខងារ និងប្រើប្រាស់សមត្ថភាព ទេពកោសល្យក្នុងជីវភាពសង្គម
- បង្កើត និងលើកទឹកចិត្តដល់អង្គការសង្គម និងផ្នែកឯកជនឱ្យបង្កើត៖
    - មជ្ឈមណ្ឌលស្តារកាយសម្បទា និងសតិបញ្ញា
    - សាលាសម្រាប់បណ្តុះបណ្តាលអ្នកបច្ចេកទេសផលិតឧបករណ៍ទ្រទ្រង់រាងកាយ
    - មជ្ឈមណ្ឌលផលិតគ្រឿងផ្សំ ឧបករណ៍ទ្រទ្រង់រាងកាយដើម្បីធានាសេចក្តីត្រូវការនៃមជ្ឈមណ្ឌលស្តារកាយសម្បទានានាក្នុងការផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយដល់ជនពិការ
- ការបង្កើតមជ្ឈមណ្ឌលស្តារកាយសម្បទា សតិបញ្ញា និងមជ្ឈមណ្ឌលផលិតគ្រឿងផ្សំឧបករណ៍ទ្រទ្រង់រាងកាយត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច

## ៤.៤. ច្បាប់ស្ដីស្ដីសុំកូនអន្តរប្រទេស

### ៤.៤.១.អាជ្ញាធរកណ្តាលស្នុំកូនអន្តរប្រទេស

- រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការស្នុំកូនអន្តរប្រទេស
- ធ្វើសហប្រតិបត្តិការ និងធ្វើការសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នាទាក់ទងនឹងកិច្ចការស្នុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការស្នុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអាជ្ញាធរកណ្តាលនិងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្នុំកូនអន្តរប្រទេសនៃប្រទេសទទួល
- ចាត់វិធានការសមស្របដើម្បីបង្ការ និងទប់ស្កាត់ ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំនេញផ្សេងៗទៀតទាក់ទងនឹងស្នុំកូនអន្តរប្រទេស
- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការស្នុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ
- ពិនិត្យលើសំណើរបស់រដ្ឋបាលស្នុំកូនអន្តរប្រទេសទាក់ទងនឹងករណីស្នុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់
- ធ្វើអធិការកិច្ចលើកិច្ចការពាក់ព័ន្ធស្នុំកូនអន្តរប្រទេស។ គ្មានជនណាអាចរារាំង បង្អាក់ ឬជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ
- ចំពោះភារកិច្ចផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការស្នុំកូនអន្តរប្រទេសដោយអនុលោមទៅតាមច្បាប់ និងនទបញ្ញាជាធរមាននៃព្រះរាជាចក្រកម្ពុជា។

### ៤.៤.២.រដ្ឋបាលស្នុំកូនអន្តរប្រទេស

- រៀបចំថែរក្សាបញ្ជីសម្ងាត់ និងសំណុំឯកសាររបស់កុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់ស្នុំកូនអន្តរប្រទេស
- វាយតម្លៃស្ថានភាពកុមារទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីសង្ងាត់ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និងធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ
- ប្រឹងប្រែងរកដំណោះស្រាយឱ្យអស់លទ្ធភាពក្នុងប្រទេស ក្នុងការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬនៅជាមួយអ្នកអាណាព្យាបាល មុននឹងដំណើរការស្នុំកូនអន្តរប្រទេស
- ទទួលពិនិត្យ និងចាត់ការពាក្យស្នុំកូនអន្តរប្រទេស និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់អ្នកសុំ
- ផ្គូផ្គងអ្នកសុំជាមួយកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់ស្នុំកូនអន្តរប្រទេស និងផ្តល់មតិយោបល់លើករណីស្នុំកូនអន្តរប្រទេសជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច
- ផ្តល់ដំណឹងទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ឬទីភ្នាក់ងារស្នុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល អំពីនីតិវិធីស្នុំកូន និងការវិវឌ្ឍនៃករណីស្នុំកូន
- សម្របសម្រួលការប្រគល់កុមារទៅឱ្យអ្នកសុំ និងរៀបចំឯកសារដើម្បីឱ្យកុមារកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ
- ផ្តល់ ឬសម្របសម្រួលការផ្តល់សេវាក្រោយស្នុំកូនសមស្របដល់កុមារ គ្រួសារអ្នកសុំ និងគ្រួសារបង្កើតតាមការចាំបាច់
- ផ្តល់មតិយោបល់ទាក់ទងនឹងការផ្តល់ការអនុញ្ញាតឱ្យទីភ្នាក់ងារស្នុំកូនអន្តរប្រទេសធ្វើប្រតិបត្តិការស្នុំកូនអន្តរប្រទេស ឬការដកហូតការអនុញ្ញាតិជូនអាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការស្នុំកូនអន្តរប្រទេ